# យន្តការបញ្ជូនឆ្លងដែនរបស់ក្រុមការងារខមមីត (COMMIT)

## សាវតា

យន្តការបញ្ជូនថ្នាក់ជាតិ (NRMs) គឺជាមុខងារសំខាន់ក្នុងកិច្ចខិតខំប្រឹងប្រែងដើម្បីកំណត់និងពង្រីកសេវាដល់បុគ្គលដែលមានតម្រូវការគាំទ្រផ្សេងៗ។ ថ្វីបើមានវិធីសាស្ត្រនិងបរិបទខុសគ្នាក៏ដោយ NRMs ជាទូទៅផ្អែកលើមូលដ្ឋានរួមដូចគ្នា។ ក្នុងន័យនេះ ការឆ្លើយតបប្រកបដោយប្រសិទ្ធភាពនិងស័ក្តិសិទ្ធិភាពត្រូវតែមានពហុជំនាញ ការសម្របសម្រួល ការរៀបចំជាប្រព័ន្ធ និង ចីរភាព។

ចំណុចស្នូលរបស់យន្តការបញ្ជូនថ្នាក់ជាតិ (NRMs) គឺជាយន្តការក្របខណ្ឌស្ថាប័នដែលមានអ្នកពាក់ព័ន្ធផ្សេងៗ ទាំងស្ថាប័នរដ្ឋាភិបាល និងស្ថាប័នមិនមែនរដ្ឋាភិបាលដែលមានអាណត្តិ និងទទួលខុសត្រូវផ្តល់សេវារហ័ស និងមានគុណភាពខ្ពស់និងទូលំទូលាយដល់អ្នកដែលត្រូវការជំនួយផ្សេងៗ។ ពួកគេធ្វើការឈរលើមូលដ្ឋាននៃបណ្តាញទំនាក់ទំនងប្រកបដោយប្រសិទ្ធភាព និងមាននីតិវិធីនិងពិធីសារដែលបានបង្កើតឡើងដោយចូលរួមសកម្មភាពពីតួអង្គពាក់ព័ន្ធ។

ការសម្របសម្រួលធ្វើឡើងទាំងតាមរយៈខ្សែបណ្តោយនិងខ្សែទទឹង ព្រមទាំងអ្នកពាក់ព័ន្ធនៅថ្នាក់ខេត្ត និងថ្នាក់មូលដ្ឋាន នៅទូទាំងប្រទេស។ ការសម្របសម្រួលអាចមានការចូលរួមពីតួអង្គក្រៅពីកម្រិតថ្នាក់ជាតិ តាមរយៈការកសាងយន្តការបញ្ជូនឆ្លងដែន (NRM) ដែលមានការចូលរួមពីប្រទេសនានា។

## យន្តការបញ្ជូនថ្នាក់ជាតិនិងឆ្លងដែនក្នុងក្របខណ្ឌខមមីត

**ខមមីត** (COMMIT) ទទួលស្គាល់និងធ្វើការឆ្ពោះទៅកាន់ការបង្កើតយន្តការបញ្ជូនជនរងគ្រោះដោយអំពើជួញដូរ។ នៅក្នុងឆ្នាំ ២០០៤ សមាជិក នៃអនុស្សារណៈនៃការយោគយល់គ្នា (MOU) បានប្តេជ្ញាចិត្ត ដូចតទៅ៖

- អនុម័តគោលការណ៍ណែនាំសមស្របនិងផ្តល់វគ្គបណ្តុះបណ្តាលដល់មន្ត្រីពាក់ព័ន្ធដើម្បីអនុញ្ញាតឱ្យមានការកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្សបានរហ័សនិងត្រឹមត្រូវ មាត្រា៨ នៃMOU។
- ផ្តល់ជូនជនរងគ្រោះដោយអំពើជួញដូរមនុស្ស នូវជម្រក និងជំនួយថៃទាំសុខភាពផ្លូវកាយផ្លូវចិត្ត ផ្លូវច្បាប់ ការអប់រំ និងសុខភាព មាត្រា១៧ នៃMOU។
- អនុម័តគោលនយោបាយ និងយន្តការនានា ដើម្បីការពារ និងគាំទ្រដល់ជនរងគ្រោះដោយអំពើជួញដូរ មាត្រា១៨ នៃMOU។

ការប្តេជ្ញាចិត្តទាំងនេះត្រូវបានបញ្ជាក់ជាថ្មីនិងពង្រឹងបន្ថែមទៀតជាថ្មីម្តងទៀតនៅក្នុងផែនការសកម្មភាពរបស់ខមមមីតលើកទី៤ (SPA IV) ។ នៅក្នុង ផែនការសកម្មភាពរបស់ខមមមីតលើកទី៤ (SPA IV) សមាជិក COMMIT យល់ព្រមផ្តល់នូវលទ្ធផល ដូចខាងក្រោម៖

- ធ្វើឱ្យមានស្តង់ដានូវនីតិវិធីសម្រាប់ការកំណត់អត្តសញ្ញាណក្នុងតំបន់ផ្អែកលើសូចនាករនៃអំពើជួញដូរមនុស្សដែលព្រមព្រៀងរួមគ្នា អនុវត្តរួមគ្នា និងសើរើរួមគ្នា។
- ដាក់ឱ្យដំណើរការនូវយន្តការបញ្ជូនថ្នាក់ជាតិដើម្បីគាំទ្រដល់ជនរងគ្រោះដោយអំពើជួញដូរ (សូចនាករ ៤.២)។

បាននាំឱ្យមានសេចក្តីព្រាងនិងអនុម័តលើឯកសារសំខាន់ៗចំនួនពីរគឺការកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរនិងទម្រង់នៃការកេងប្រវ័ញ្ច៖ **១.សូចនាករទូទៅសម្រាប់អ្នកឆ្លើយតបដំបូង** [[សូចនាករខមមីត] និង **២.ការកំណត់អត្តសញ្ញាណជនរងគ្រោះនិងយន្តការបញ្ជូន៖** គោលការណ៍ណែនាំរួមសម្រាប់មហាអនុតំបន់មេគង្គ។ [**គោលការណ៍ណែនាំខមមីត**] នៅឆ្នាំ ២០១៦។

ក្រោយមកទៀតផ្តល់នូវមូលដ្ឋានគ្រឹះសម្រាប់ការបង្កើតនៅយន្តការបញ្ជូនថ្នាក់ជាតិ (NRMs)/យន្តការបញ្ជូនឆ្លងដែន(TRM) ក្នុងCOMMIT ដោយផ្អែកលើគោលការណ៍គ្រឹះដូចខាងក្រោម៖

- គោលការណ៍សិទ្ធិមនុស្សសម្រាប់ជនរងគ្រោះដោយអំពើជួញដូរ។
- ជនរងគ្រោះដោយការសន្មតទទួលបានជំនួយរហូតដល់ការកំណត់អត្តសញ្ញាណត្រូវបានបញ្ចប់។

- គោរពភាពឯកជនរបស់ជនរងគ្រោះនិងការសម្ងាត់នៃព័ត៌មានរបស់ជនរងគ្រោះ។
- ការឆ្លើយតបដោយយល់ដឹងអំពីយេនឌ័រ។
- ផ្តល់អាទិភាពដល់ឧត្តមប្រយោជន៍របស់កុមារ។
- ការផ្តល់ជូនសេវាគ្រប់ជ្រុងជ្រោយ និងមានគុណភាពខ្ពស់។
- ការទទួលបានព័ត៌មាន រួមមានសិទ្ធិនិងជម្រើសជាភាសាដែលជនរងគ្រោះអាចយល់បាន

**ផ្នែកទាំង៦នៃគោលការណ៍របស់** COMMIT **មានដូចជា៖**

1. ការបកស្រាយស្មារតីនៃMOU
2. ធ្វើសម្ភាសន៍បឋម និងការបញ្ជូន
3. ជំនួយបណ្តោះអាសន្ន
4. រយៈពេលនៃការជាសះស្បើយឡើងវិញ និងការឆ្លុះបញ្ចាំង
5. ការកំណត់អត្តសញ្ញាណជាផ្លូវការ
6. សេវាបញ្ជូន ព័ត៌មាន និងសេវាគាំទ្រ។

គោលការណ៍ណែនាំរបស់ខមមីតដែលមានគោលការណ៍ណែនាំភាគច្រើនអនុលោមទៅតាមស្តង់ដារអន្តរជាតិដែលបង្កើតឡើងសម្រាប់យន្តការបញ្ជូន **ហើយជំហានបន្ទាប់ទៀតគឺជាការប្រតិបត្តិ**។

**រៀបចំបង្កើតយន្តការបញ្ជូនសម្រាប់ខមមីត៖**

យន្តការបញ្ជូនថ្នាក់ជាតិ (NRMs) ដែលត្រូវបានបង្កើតឡើងនៅក្នុងប្រទេសមហាអនុតំបន់ទន្លេមេគង្គអាចខុសគ្នាពីប្រទេសមួយទៅប្រទេសមួយ ក្រោមហេតុផលផ្សេងៗ ដូចជាប្រព័ន្ធអភិបាលកិច្ចផ្សេងគ្នា និងទំហំហេដ្ឋារចនាសម្ព័ន្ធពាក់ព័ន្ធមានរួចហើយ។ ហេតុដូច្នេះហើយ **គ្មានទម្រង់ណាដែលមានតែមួយទំហំនោះទេ** (no one-size-fits-all format) ប៉ុន្តែការណែនាំនិងដំណើរការបានផ្តល់នូវក្របខ័ណ្ឌទូលំទូលាយសម្រាប់រដ្ឋាភិបាលដើម្បីដាក់ឱ្យដំណើរការយន្តការបញ្ជូនថ្នាក់ជាតិរបស់ខ្លួន (NRMs)។

មានការរីកចម្រើនល្អខ្លះក្នុងការបង្កើតយន្តការបញ្ជូនថ្នាក់ជាតិ (NRMs) នៅគ្រប់ប្រទេសទាំងអស់។ ការប្តេជ្ញាចិត្តពីរដ្ឋាភិបាលជាសមាជិកខមមីតក្នុងការប្រើប្រាស់គោលការណ៍ណែនាំរួមស្តីពីយន្តការកំណត់អត្តសញ្ញាណនិងការបញ្ជូន ក្នុងនោះមានការប្តេជ្ញាចិត្តដែលត្រូវបានបញ្ជាក់ជាថ្មីនិងសូចនាករណាមួយដែលត្រូវបានព្រមព្រៀងគ្នាក្រោម SPAIV នៃដំណើរការខមមីត។

យន្តការបញ្ជូនឆ្លងដែន(TRM) ភ្ជាប់ជាមួយ យន្តការបញ្ជូនថ្នាក់ជាតិ (NRMs) នៅក្នុងបណ្តាប្រទេសសមាជិកCOMMIT ហើយនៅពេលដែលវាចាំបាច់ត្រូវមានភាពបត់បែនដើម្បីសម្របខ្លួនទៅនឹងភាពខុសគ្នានៃយន្តការជាតិ។ យន្តការបញ្ជូនឆ្លងដែន(TRM) ក៏ត្រូវតែផ្តល់នូវភាពសាមញ្ញគ្រប់គ្រាន់សម្រាប់ការភ្ជាប់គ្នាទៅវិញទៅមកប្រកបដោយប្រសិទ្ធភាព។ ការអភិវឌ្ឍទាំងយន្តការបញ្ជូនថ្នាក់ជាតិ (NRMs) និង យន្តការបញ្ជូនឆ្លងដែន(TRM) ទាមទារឱ្យមានការសម្របសម្រួលក្នុងតំបន់ប្រកបដោយប្រសិទ្ធភាពក្នុងអំឡុងពេលដំណើរការទាំងមូល។

អាចមានគំរូផ្សេងគ្នា នៃយន្តការបញ្ជូនឆ្លងដែន (TRM) ត្រូវបានបង្កើតឡើងដែលមានកម្រិតខុសគ្នានៃសមាហរណកម្មយន្តការបញ្ជូនឆ្លងដែន (TRM) ។

គំរូដែលត្រូវបានបង្កើតឡើងនៅក្នុងតំបន់មួយចំនួន ដូចជាអឺរ៉ុបភាគអាគ្នេយ៍ដែលមាន នីតិវិធីប្រតិបត្តិស្តង់ដា(SOP)មានលក្ខណៈលម្អិតសម្រាប់ជំហាននីមួយៗ ស្រដៀងគ្នាជាមួយ យន្តការបញ្ជូនថ្នាក់ជាតិ (NRMs) ។

UNDP អាចបន្តគាំទ្រការងារនេះតាមរយៈគម្រោងរួមគ្នាថ្មី រវាង អាយឡូ ILO និងអាយ អូ អឹម (IOM)។ គម្រោងរួមគ្នាថ្មីនេះនឹងធានាបាននូវការអភិវឌ្ឍបន្ថែមទៀតនៃយន្តការបញ្ជូនឆ្លងដែន (TRM) ខណៈដែលផ្តោតលើឧស្សាហកម្មនេសាទ នឹងតម្រូវឱ្យមានយន្តការដូចគ្នាជាច្រើនត្រូវបានអភិវឌ្ឍ។